# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៧

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ២៤៧,៧៣៤ ដុល្លារអាមេរិក សម្រាប់ការកែលម្អការថែទាំសុខភាព និងប្រព័ន្ធធារាសាស្ត្រ

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន **២៤៧,៧៣៤ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនបី។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ**ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបីសម្រាប់គម្រោងដូចតទៅ៖

**១. គម្រោងបំពាក់ឧបករណ៍បរិក្ខាពេទ្យ នៅមន្ទីរពេទ្យបង្អែកចំការលើ ខេត្តកំពង់ចាម (ថវិកាចំនួន៨២,១៨០ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំការលើ ខេត្តកំពង់ចាម

គម្រោងនេះ នឹងផ្តល់ជូននូវឧបករណ៍បរិក្ខាពេទ្យមួយឈុតរួមមាន៖ ឧបករណ៍សម្រាប់វះកាត់ និងម៉ាស៊ីនធ្វើតេស្តឈាមមួយចំនួន ដល់មន្ទីរពេទ្យបង្អែកចំការលើ ខេត្តកំពង់ចាម។ មួយនឹងគម្រោងនេះ អ្នកជម្ងឺប្រមាណជា ៦៦០នាក់ក្នុងមួយឆ្នាំ នឹងទទួលបានសេវាវះកាត់នៅមន្ទីរពេទ្យបង្អែកនេះ។

**២. គម្រោងសាងសង់អគារផ្នែកសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យបង្អែកស្ទោង ខេត្តកំពង់ធំ (ថវិកាចំនួន ៨៣,១៧៥ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរសុខាភិបាលខេត្តកំពង់ធំ

គម្រោងនេះ នឹងធ្វើការសាងសង់អគារផ្នែកសង្គ្រោះបន្ទាន់មួយខ្នង នៅមន្ទីរពេទ្យបង្អែកស្ទោង ខេត្តកំពង់ធំ។ ជាមួយនឹងគម្រោងនេះ អ្នកជម្ងឺប្រមាណជា ៦៦០នាក់ក្នុងមួយឆ្នាំ នឹងទទួលបានការព្យាបាលនៅអគារផ្នែកសង្គ្រោះបន្ទាន់ថ្មីនេះ ហើយអ្នកមកពិគ្រោះជម្ងឺក្រៅប្រមាណជា ៣,១០០នាក់ក្នុងមួយឆ្នាំ នឹងទទួលបានគុណប្រយោជន៍ពីការផ្តល់សេវាពិនិត្យបែងចែកជម្ងឺដំបូងនៅក្នុងអគារថ្មីនេះផងដែរ។

**៣. គម្រោងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្របឹងកន្សែង ខេត្តពោធិ៍សាត់ (ថវិកាចំនួន ៨២,៣៧៩ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ មន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់

គម្រោងនេះ នឹងធ្វើការស្តារប្រឡាយរងមួយខ្សែប្រវែង ២,៣១០ម៉ែត្រ ព្រមទាំងការសាងសង់សំណង់ក្បាលប្រឡាយរង១កន្លែង និងសំណង់លូ៣កន្លែង ក្នុងប្រព័ន្ធធារាសាស្ត្របឹងកន្សែង។ គម្រោងនេះត្រូវបានរំពឹងថា ប្រជាកសិករប្រមាណជា ៣,៣០០នាក់ នឹងទទួលបានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពលើដីស្រែ ហើយផ្ទៃដីដាំដុះរបស់ពួកគេ ក៏នឹងត្រូវបានពង្រីកកាន់តែច្រើន ក្រោមការស្តារប្រព័ន្ធនេះផងដែរ។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្ថាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៦លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៦៥ គម្រោងនៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល:* *eco.jpn@.pp.mofa.go.jp*
*គេហទំព័រ:* *http://www.kh.emb-japan.go.jp*